## សេចក្តីថ្លែងការណ៍រួម

# កូដកម្មបង្អត់អាហាររបស់កញ្ញា សេង ធារី បង្ហាញពីការជាប់ឃុំដោយអយុត្តិធម៌

ចេញផ្សាយថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២៥

កញ្ញា សេង ធារី ដែលជាមេធាវីសិទ្ធិមនុស្ស ជាអតីតថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងជាសកម្មជននយោបាយគណបក្សជំទាស់ដ៏មានប្រជាប្រិយភាពមួយរូប កំពុងធ្វើកូដកម្មបង្អត់អាហារជាលើកទី៤ ក្នុងពន្ធនាគារ ចាប់តាំងពីកញ្ញាបានជាប់ឃុំកាលពីខែមិថុនា ឆ្នាំ២០២២ ។ ផលប៉ះពាល់នៃការបង្អត់អាហារខ្លួនឯង ទៅលើសុខុមាលភាពរបស់កញ្ញា ធារី អាចមានទំហំធំធេង ហើយយើងខ្ញុំពិតជាមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុខភាពរបស់កញ្ញា ។ ការបន្តឃុំខ្លួនកញ្ញា គឺកាន់តែធ្វើឱ្យបញ្ហាសុខភាពរបស់កញ្ញា កាន់តែធ្ងន់ធ្ងរឡើងៗ ។

កូដកម្មបង្អត់អាហាររបស់កញ្ញា ធារី គឺមានរយៈពេល ១៤ថ្ងៃ ដោយកំណត់ធ្វើរហូតដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៥ ដើម្បីគម្រប់ខួបរយៈពេលបីឆ្នាំ ដែលកញ្ញាបានជាប់នៅក្នុងពន្ធនាគារ ។ ការធ្វើកូដកម្មនេះក៏ត្រូវបានធ្វើឡើង ក្នុងគោលបំណង ដើម្បីឱ្យមានការយកចិត្តទុកដាក់ ចំពោះការជាប់ឃុំរបស់កញ្ញាផ្ទាល់ ក៏ដូចជាអំពាវនាវឱ្យមានការដោះលែងសកម្មជននយោបាយ និងអ្នកការពារសិទ្ធិមនុស្សទាំងអស់ ដែលត្រូវបានឃុំខ្លួនក្នុងពន្ធនាគារដោយអយុត្តិធម៌ ។

កញ្ញា ធារី ដែលមានសញ្ជាតិខ្មែរ-អាមេរិកាំង ត្រូវបានតុលាការផ្តន្ទាទោស ក្នុងសំណុំរឿងដ៏ធំមួយជាមួយនឹងសកម្មជនគណបក្សជំទាស់ជាច្រើននាក់ផ្សេងទៀត ដោយត្រូវបានតុលាការកំណត់ទោសរយៈពេល ៦ឆ្នាំ ក្នុងពន្ធនាគារពីបទ ញុះញង់ និងរួមគំនិតក្បត់ ។ កញ្ញា ធារី ត្រូវបានចាប់ខ្លួននៅខាងក្រៅសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ ខណៈពេលដែលកញ្ញាកំពុងតវ៉ាដោយអហិង្សាចំពោះបទចោទប្រកាន់ទាំងនោះ ដោយស្លៀកសម្លៀកបំពាក់ជារូបសំណាកនៃសេរីភាព ។ ក្រុមការងារអង្គការសហប្រជាជាតិ ស្តីពីការឃុំខ្លួនតាមអំពើចិត្ត បានលើកឡើងថា ការឃុំខ្លួនកញ្ញា ធារី គឺព្រោះតែការអនុវត្តសិទ្ធិសេរីភាពរបស់កញ្ញា ក្នុងការបញ្ចេញមតិ ការប្រមូលផ្តុំ និងបង្កើតសមាគមដោយសន្តិវិធីរបស់កញ្ញា ហើយចាត់ទុកការឃុំខ្លួននេះ ជាសកម្មភាពដែលមិនត្រឹមត្រូវ និងជាការរើសអើងផ្នែកនយោបាយ ។

យើងខ្ញុំគាំទ្រដល់ការអំពាវនាវក្រុមការងារអង្គការសហប្រជាជាតិស្ដីពីការឃុំខ្លួនតាមអំពើចិត្ត និងស្នើសុំឱ្យរាជរដ្ឋាភិបាល សូមបញ្ឈប់ការរឹតត្បិតសេរីភាពរបស់កញ្ញា ធារី និងសូមដោះលែងកញ្ញា ធារី ជាបន្ទាន់និងឥតលក្ខខណ្ឌ ។ យើងខ្ញុំនឹងនៅបន្តឈរជាមួយនឹងកញ្ញា ធារី សង្ឃឹមថាកញ្ញានឹងមានសុខភាពល្អ ហើយសង្ឃឹមថាសកម្មភាពរបស់កញ្ញា នឹងនាំមកនូវយុត្តិធម៌ចំពោះសកម្មជននយោបាយ និងអ្នកការពារសិទ្ធិមនុស្សគ្រប់រូបទាំងអស់ ដែលត្រូវបានជាប់ឃុំយ៉ាងអយុត្តិធម៌ក្នុងពន្ធនាគារ ៕

**សេចក្ដីថ្លែងការណ៍រួមនេះចូលរួមគាំទ្រដោយៈ**

១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
២. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
៣. សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិនុស្ស លីកាដូ (LICADHO)
៤. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់)
៥. អង្គការសមធម៌កម្ពុជា (EC)
៦. អង្គការសមាគមធាងត្នោត (សធត)